មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# របាយការណ៍បូកសរុបប្រចាំឆ្នាំ២០១៦ របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

| | |
|---|---|
| **ឈ្មោះស្ថាប័ន** | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") |
| **គោលដៅ** | ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឲ្យកម្ពុជាក្លាយទៅជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសមភាពនិងត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យនិងទទួលបានប្រយោជន៍ពីការអភិវឌ្ឍប្រទេស។ |
| **រយៈពេល** | ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០១៦ ។ |

ក្នុងអំឡុងឆ្នាំ២០១៦ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានអនុវត្តន៍ការងារសកម្មភាពរបស់ខ្លួនដូចមានរៀបរាប់ខាងក្រោមនេះ ៖

## I. វឌ្ឍនភាពនៃសកម្មភាព

ក្នុងអំឡុងរយៈពេលនៃរបាយការណ៍នេះ ម.ស.ម.ក បានចេញផ្សាយឯកសារបោះពុម្ពផ្សាយចំនួន ៨០ រួមមានសេចក្តីថ្លែងការណ៍ និងលិខិតចំហ សេចក្តីថ្លែងការណ៍រួម សេចក្តីប្រកាសព័ត៌មានទាក់ទងនឹងអ្នកការពារសិទ្ធិមនុស្ស និង/ឬសេរីភាពបញ្ចេញមតិ កំណត់ត្រាសង្ខេប របាយការណ៍ស្រាវជ្រាវ សលាកបត្រព័ត៌មាន ការវិភាគច្បាប់ សារណា គោលនយោបាយសង្ខេប និងខិត្តប័ណ្ណអប់រំជាដើម ។ ឯកសារទាំងនេះត្រូវបានចេញផ្សាយដើម្បីស្វែងរកការគាំទ្រមតិ និងលើកកម្ពស់ការយល់ដឹងពីបញ្ហាសិទ្ធិមនុស្សផ្សេងៗ រួមមានសេរីភាពជាមូលដ្ឋាន សិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស ការចូលរួមផ្នែកនយោបាយ និងផ្សេងៗទៀត។ ឯកសារចេញផ្សាយរបស់ ម.ស.ម.ក បាននាំអោយអាជ្ញាធរចាត់វិធានការ ជាការឆ្លើយតបទៅនឹងការរំលោភបំពានសិទ្ធិមនុស្ស។ ម.ស.ម.ក បានចេញសេចក្តីថ្លែងការណ៍ប្រកបដោយគោលការណ៍ ឆ្លើយតបទៅនឹងព្រឹត្តិការណ៍នានានាពេលបច្ចុប្បន្ន ដោយមានអត្ថបទសារព័ត៌មានចំនួន ២១១ បានចេញផ្សាយទាំងភាសាខ្មែរ និងអង់គ្លេសនៅក្នុងឆ្នាំ២០១៦ ដែលបានចេញផ្សាយពីការងាររបស់ ម.ស.ម.ក ។

ជាលទ្ធផលនៃការឃ្លាំមើលសារព័ត៌មានកំពុងបន្តនៅក្នុងឆ្នាំ២០១៦ ការងារគម្រោងរបស់ ម.ស.ម.ក ទទួលបានព័ត៌មានថ្មីៗជុំវិញព្រឹត្តិការណ៍នាពេលបច្ចុប្បន្ន និងបញ្ហាសំខាន់ៗនៅទូទាំងប្រទេសកម្ពុជា។ ជាសរុបក្នុងអំឡុងរយៈពេលនៃរបាយការណ៍នេះ ម.ស.ម.ក បានប្រមូលអត្ថបទសារព័ត៌មានចំនួន ៣២៦១ ដោយក្នុង

នោះមានករណីចំនួន ៤៤៥ ទាក់ទងទៅនឹងសេរីភាពខាងសមាគម និងសេរីភាពមូលដ្ឋានផ្សេងៗទៀតត្រូវបានកត់ត្រាទុក ហើយករណីចំនួន ៧៣ ត្រូវបានចងក្រង។ ជាងនេះទៀត ម.ស.ម.ក ក៏បានតាមដានអនុក្រឹត្យដែលបានចេញផ្សាយតាមរយៈព្រះរាជកិច្ចដើម្បីកត់ត្រាទុកចំនួននៃការផ្តល់សម្បទានដីផងដែរ។ ម.ស.ម.ក រកឃើញថា ខណៈដែលពុំមានការផ្តល់សម្បទានដីសេដ្ឋកិច្ចដែលនេះបង្ហាញថា រដ្ឋាភិបាលបានគោរពតាមបទបញ្ជាផ្អាកការផ្តល់សម្ប ទានដីបណ្តោះអាសន្នដែលបានចេញនៅពាក់កណ្តាលឆ្នាំ២០១២ ប៉ុន្តែក៏មានការធ្វើអនុបយោគដីចំនួន១៩,៤៥៩ ពីដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋ។ ម.ស.ម.ក ក៏រកឃើញផងដែរថាពុំមានការផ្តល់សម្បទានដីសង្គមកិច្ចក្នុងអំឡុងពេលឆ្នាំ២០១៦ ឡើយ។

ម.ស.ម.ក បានបង្កើតទម្រង់ឃ្លាំមើលថ្មីៗ ដែលជាវិធីសាស្ត្រមានលក្ខណៈជាប្រព័ន្ធបន្ថែមទៀតដើម្បីកត់ត្រានូវទិន្នន័យព័ត៌មានប្រកបដោយបរិមាណ និងគុណភាពអំពីការរំលោភបំពានទៅលើសេរីភាពជាមូលដ្ឋាននានា។ គម្រោងបានធ្វើការស្ទង់មតិសាធារណជន ដោយប្រមូលបានការឆ្លើយតបចំនួន១០១៧ នៅទូទាំងប្រទេសដែលបានផ្តល់នូវទិន្នន័យសំខាន់អំពីស្ថានភាពសេរីភាពជាមូលដ្ឋានក្នុងឆ្នាំ២០១៦។ ទិន្នន័យនេះត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍តាមរយៈឧបករណ៍កត់ត្រាទិន្នន័យព័ត៌មានប្រចាំត្រីមាសទីពីររបស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន។ មានការស្ទង់មតិថ្នាក់ដឹកនាំសហជីព/អង្គការសង្គមស៊ីវិលអំពីសេរីភាពខាងសមាគមនិងបញ្ហាដែលពាក់ព័ន្ធផ្សេងទៀតត្រូវបានធ្វើឡើងក្នុងខែតុលានិងខែវិច្ឆិកា។ មានអ្នកឆ្លើយតបចំនួន ២១៤ នាក់ ហើយទិន្នន័យនោះនឹងត្រូវបញ្ចូលទៅក្នុងរបាយការណ៍តាមរយៈឧបករណ៍កត់ត្រាទិន្នន័យព័ត៌មានប្រចាំត្រីមាសទីបី។ របាយការណ៍ប្រចាំត្រីមាសទីពីរនៃគម្រោងនេះបានបង្កើតរួចរាល់ហើយនូវទិន្នន័យថ្មី និងការវិភាគទាក់ទងទៅនឹងនិន្នាការដែលមើលពុំឃើញនាពេលកន្លងមក។ លទ្ធផលទទួលបានពីសកម្មភាពឃ្លាំមើលទាំងនោះ ម.ស .ម.ក បានផលិតនូវឯកសារមួយចំនួនតួយ៉ាងដូចជាឯកសារ កាលប្បវត្តិនៃករណីរំលោភសិទ្ធិមនុស្ស ដែលបានចេញផ្សាយនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៦ និងសលាកបត្រព័ត៌មានផ្សេងទៀតស្តីពី ស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ចេញផ្សាយក្នុងខែធ្នូ ឆ្នាំ២០១៦។

លើសពីនេះ ម.ស.ម.ក បានរៀបចំការផ្សាយផ្ទាល់នូវកម្មវិធីវិទ្យុយ៉ាងតិចចំនួន១៦៥ លើក ដោយកម្មវិធីនីមួយៗផ្តោតទៅលើប្រធានបទដែលបានរៀបរាប់ខាងលើ ក្នុងនោះរួមមានកម្មវិធីពិភាក្សាទាក់ទងនឹងសិទ្ធិដីធ្លី ធុរកិច្ច និងសិទ្ធិមនុស្ស សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិរបស់អ្នកស្រលាញ់ភេទដូចគ្នា សិទ្ធិបច្ចេកវិទ្យា ច្បាប់ និងកម្មវិធីវិភាគប្រចាំសប្តាហ៍។ ម.ស.ម.ក បានរៀបចំកម្មវិធីជំនួបសកម្មជនមួយលើក កម្មវិធីផ្សព្វផ្សាយរបាយការណ៍ចំនួន ៤ ដង ហើយនិងកម្មវិធីបណ្តុះបណ្តាលចំនួន ៩ អំពីប្រធានបទផ្សេងៗ ចាប់តាំងពីសន្តិសុខផ្នែកបច្ចេកវិទ្យា ជំនាញសម្របសម្រួល ច្បាប់ភូមិបាល ជំនាញចងក្រងឯកសារ និងការតស៊ូមតិ និងវគ្គបណ្តុះបណ្តាលគ្រូបង្គោលចំនួនពីរលើក។ ដោយឡែកពីនេះ ម.ស.ម.ក បានរៀបចំវគ្គចែករំលែកចំនួនបីលើកផ្សេងទៀតពាក់ព័ន្ធនឹងសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នាដោយមានការចូលរួមពីនិស្សិតសាកលវិទ្យាល័យចំនួន ១៩៥ នាក់ ក្នុងខេត្តចំនួនបី ។ ក្នុងឆ្នាំ២០១៦ ម.ស.ម.ក បានសង្កេតសវនាការចំនួន៩៨ ករណីនៅសាលាឧទ្ធ

រណ៍។ ជារួម ករណីចំនួន ៣៥ ទទួលបានមេធាវីការពារ ឬការប្រឹក្សាយោបល់ផ្នែកច្បាប់ និងការគាំទ្រផ្នែកមនុស្សធម៌ពី ម.ស.ម.ក ។

ជាក់ស្តែង ម.ស.ម.ក បានធ្វើសកម្មភាពផ្សេងៗដើម្បីស្វែងរកការគាំទ្រមតិផងដែរ។ តាមរយៈគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ផ្អែកលើរបកគំហើញនានានៃរបាយការណ៍ *ការសម្លុតអ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀនក្នុងប្រទេសកម្ពុជា*។ លទ្ធផលនៃរបាយការណ៍នេះបានបង្ហាញពីលក្ខណៈវិជ្ជមានណាស់មួយចំនួនដូចជា បន្ទាប់ពីកិច្ចប្រជុំនានាជាមួយក្រសួងមួយចំនួន ដូចជាក្រសួងកិច្ចការនារី និងក្រសួងអប់រំយុវជន និងកីឡា បានឆ្លើយតបយ៉ាងវិជ្ជមាន។ បច្ចុប្បន្ននេះក្រសួងកិច្ចការនារីរៀបចំកិច្ចប្រជុំប្រចាំខែអំពីបញ្ហានេះហើយក្រសួងព័ត៌មានបានទទួលស្គាល់ថានេះជាបញ្ហាចាំបាច់ដើម្បីបញ្ចៀសផ្នត់គំនិតមិនល្អទៅលើអ្នកស្រលាញ់ភេទដូចគ្នានៅលើបណ្តាញផ្សព្វផ្សាយព័ត៌មាន។ ម.ស.ម.ក ក៏ទទួលបានជោគជ័យផងដែរបន្ទាប់ពីចេញផ្សាយរបាយការណ៍ស្តីពី*ការរើសអើងលើអ្នកប្តូរភេទជាស្ត្រីនៅតាមទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា*។ ប្រភពព័ត៌មានមួយចំនួនបានផ្សព្វផ្សាយរបាយការណ៍ផងដែរ។ នេះរួមទាំងការប្រជុំក្នុងខែធ្នូជាមួយអភិបាលរងខេត្តសៀមរាបដើម្បីតស៊ូមតិសម្រាប់ការអនុវត្តអនុសាសន៍នានាក្នុងរបាយការណ៍ *ការរើសអើងលើអ្នកប្តូរភេទជាស្ត្រីនៅតាមទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។* ជាងនេះទៅទៀតនោះ ម.ស.ម.ក ក៏បានជួបជាមួយតំណាងក្រសួងកិច្ចការនារីគឺលោកជំទាវ ប៉ិនឈិត វាសនា និងសហការីចំនួនពីរនាក់របស់លោកជំទាវដើម្បីបង្ហាញពីរបកគំហើញ និងអនុសាសន៍ទាក់ទងនឹងស្ត្រីអ្នកការពារសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា។

ម.ស.ម.ក ក៏បានផលិតវីដេអូអប់រំចំនួនពីរផងដែរ ក្នុងគោលបំណងលើកកម្ពស់សេរីភាពខាងការបញ្ចេញមតិនៅលើបណ្តាញអ៊ីនធឺណិត។ វីដេអូអប់រំទី១ ស្តីពី "សេរីភាពខាងការបញ្ចេញមតិ" ត្រូវបានផលិតឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងដល់សាធារណជនអំពីសេរីភាពខាងការបញ្ចេញមតិ។ វីដេអូនេះត្រូវបានផ្សព្វផ្សាយនៅលើយូធូប របស់ ម.ស.ម.ក និងទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក។ វីដេអូនោះបានទទួលការចាប់អារម្មណ៍ជាខ្លាំងនៅលើបណ្តាញហ្វេសប៊ុកដោយមានអ្នកចែករំលែកបន្តចំនួន៩៧៣ អ្នកចុច likes ចំនួន១,៤០០ និងអ្នកចូលទៅមើល[1]ចំនួន ៤៣,០០០ (រហូតមកដល់ត្រឹមថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧)។ វីដេអូទី ២ ស្តីពី "ការបញ្ចេញមតិលើបណ្តាញអ៊ីនធឺណិត" ត្រូវបានផលិតឡើងក្នុងគោលបំណងលើកកម្ពស់សេរីភាពខាងការបញ្ចេញមតិ និងគំនិតនៅលើអ៊ីនធឺណិតព្រមទាំងដើម្បីកាត់បន្ថយការដាក់ពិរុទ្ធលើគំនិតខ្លួនឯងរបស់សាធារណជននៅលើបណ្តាញផ្សព្វផ្សាយសង្គម ដោយសារតែខ្លាចការចោទប្រកាន់ពីបទបរិហារកេរ្តិ៍។ ដូចគ្នានេះដែរ វីដេអូចលនាដំបូងស្តីពី "ការបញ្ចេញមតិលើបណ្តាញអ៊ីនធឺណិត" ត្រូវបានផ្សព្វផ្សាយតាមរយៈយូធូបរបស់ ម.ស.ម.ក និងទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក។ វីដេអូនោះត្រូវបានចែករំលែកបន្តចំនួន ៤៨៧ ចុច Likes ចំនួន ៧៦៧ និងចូលទៅមើលចំនួន ២៩,០០០ (រហូតមកដល់ត្រឹមថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧)។ ម្យ៉ាងទៀត ម.ស.ម.ក ព្រមទាំងបានផលិតវីដេអូដែលលើកឡើងនូវមតិសាធារណជនអំពីច្បាប់ទាក់ទងនឹងប្រព័ន្ធអ៊ីន

[1] ទស្សនា៖ ពេលវេលាមួយចំនួនដែលបង្ហោះត្រូវបានវាយតម្លៃរយៈពេលយ៉ាងតិចបីនាទី ប្រភព ៖ http://bit.ly/1upJLvd

ធីណិត ដែលបានជួយសម្រួលឱ្យមានការពិភាក្សាអំពីសេចក្ដីស្នើច្បាប់ស្ដីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា ដោយទទួលបានការចែករំលែកបន្តចំនួន ២២៥ ចុច likes ចំនួន ៧០ និងចូលទៅទស្សនាចំនួន ៥៤,០០០ (គិតមកដល់ត្រឹមថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧)។ ក្នុងខែមិថុនា ឆ្នាំ២០១៦ ម.ស.ម.ក ក៏បានផលិតខិតប័ណ្ណអប់រំទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ និងការកម្រិតលើសេរីភាពនេះក្រោមច្បាប់អន្តរជាតិក្នុងគោលបំណងដើម្បីលើកកម្ពស់ការយល់ដឹងអំពីវិសាលភាពដែលអនុញ្ញាតការរឹតត្បិតទៅលើការបញ្ចេញមតិនៅលើបណ្ដាញអ៊ីនធឺណិត។

## II. សកម្មភាពដែលដំណើរការបានល្អ និងមិនល្អ

មានចំនុចជោគជ័យជាច្រើនសម្រាប់សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា តាមរយៈគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។ ការចេញផ្សាយរបាយការណ៍ស្ដីពីការរើសអើងលើអ្នកប្ដូរភេទជាស្ត្រីនៅតាមទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា បានធ្វើឱ្យមានឥទ្ធិពលលើការរើសអើងលើអ្នកស្រលាញ់ភេទដូចគ្នា ព្រោះមានការទទួលស្គាល់ជាវិជ្ជមានអំពីបញ្ហានេះ។ របាយការណ៍នេះក៏ផ្ដល់ជាមូលដ្ឋានរឹងមាំសម្រាប់ការតស៊ូមតិផងដែរ។

លើសពីនេះទៀត ម.ស.ម.ក បានរកឃើញថាមានការកើនឡើងនូវការរឹតត្បិតទៅលើសេរីភាពមូលដ្ឋាន ដោយរកឃើញថាតំណាងសហគមន៍ខ្លះនៅតាមខេត្តមួយចំនួនបានប្រឈមនឹងការធ្វើទុក្ខបុកម្នេញ និងការគំរាមកំហែង ដូចជា ការរារាំងពួកគាត់ក្នុងការទាក់ទងជាមួយភាគីពាក់ព័ន្ធខាងក្រៅដើម្បីចូលរួមប្រជុំ និងការបណ្ដុះបណ្ដាលជាមួយអង្គការជាដើម។ សកម្មជនមួយចំនួនត្រូវបានឃ្លាំមើលយ៉ាងជិតដល់ពីសំណាក់នគរបាល ហើយអាជ្ញាធរមូលដ្ឋានបានហាមប្រាមការជួបប្រជុំ ឬសម្ភាសន៍ក្នុងភូមិ តាមរយៈការល្បាតដើម្បីធ្វើការរឹតត្បិតលើសកម្មភាពទាំងនេះ។ ការចូលរួមរបស់អាជ្ញាធរមូលដ្ឋានមានសារៈសំខាន់ និងចាំបាច់ត្រូវមានការពន្យល់ឱ្យបានត្រឹមត្រូវនូវគោលបំណងនៃគម្រោងនានា ដែលពុំត្រូវឱ្យគេលើកឡើងដោយបំផ្លើសបាន។ ប្រសិនបើទទួលបានការពន្យល់ត្រឹមត្រូវ នោះអាជ្ញាធរមូលដ្ឋានអាចយល់ និងទទួលស្គាល់ពីសកម្មភាពនានារបស់គម្រោង។

## III. មេរៀន

ម.ស.ម.ក យល់ឃើញថាការអនុវត្តឱ្យបានជាប់លាប់ក្នុងវិធីសាស្ត្រតស៊ូមតិនិងការគៀរគរឲ្យមានកិច្ចសន្ទនា និងការចូលរួមពីភាគីពាក់ព័ន្ធអាចនាំមកនូវលទ្ធផលជាក់លាក់។ កំណត់ត្រាសង្ខេបស្ដីពី*ផលប៉ះពាល់ផ្នែកសិទ្ធិមនុស្សដោយសារការបូមខ្សាច់នៅកម្ពុជា*បានទាញឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធជាច្រើនជាពិសេសពីក្រសួងរ៉ែនិងថាមពល។ កិច្ចប្រឹងប្រែងនេះទទួលបានលទ្ធផលជាវិជ្ជមានខ្លាំងណាស់ ដោយក្រសួងរ៉ែ និងថាមពលបានផ្លាស់ប្ដូរនូវគោលនយោបាយពាក់ព័ន្ធនឹងការបូមខ្សាច់។ ម្យ៉ាងទៀត ក្រសួងរ៉ែនិងថាមពលបានបង្ហាញពីឆន្ទៈក្នុងការបើកកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិល តាមរយៈការចូលរួមក្នុងបេសកកម្មស្វែងរកការពិតរួមគ្នាទៅកាន់ខេត្តកោះកុងដើម្បីស៊ើបអង្កេតករណីបូមខ្សាច់ខុសច្បាប់។ ចាប់តាំងពីក្រសួងរ៉ែ និងថាមពល បានចុះទៅកាន់ភូមិកោះស្រឡៅ និងភូមិដាក់ពោធិ៍ សហគមន៍ដែលរងផលប៉ះពាល់ទាំងពីរបានមានទំនាក់ទំនងជាមួយក្រសួងរ៉ែនិងថាមពលផ្ទាល់ តាមរយៈបណ្ដាញទូរសព្ទផ្ដល់ព័ត៌មានទាន់ហេតុការណ៍របស់

ក្រសួង។ ក្រសួងរ៉ែ និងថាមពលបានគូសបញ្ជាក់ថាជីវភាពរបស់ពលរដ្ឋទាំងនោះ និងដីស្រែនឹងមិនរងប៉ះពាល់តទៅទៀតឡើយ ហើយបណ្ដាញទំនាក់ទំនងនេះគឺជាឧបករណ៍សំខាន់មួយសម្រាប់ធានានូវជីវភាពជានិរន្តរ៍របស់ពួកគេ។

## IV. យេនឌ័រ និងគោលការណ៍ផ្អែកលើសិទ្ធិជាមូលដ្ឋាន

ម.ស.ម.ក ប្រឹងប្រែងដើម្បីសម្រេចបានសមភាពយេនឌ័រតាមរយៈកម្មវិធី និងគម្រោងនានាទាំងអស់របស់ខ្លួន។ នៅឆ្នាំ២០១៦ ម.ស.ម.ក ព្យាយាមជំនះនូវឧបសគ្គនានាដើម្បីឱ្យមានការចូលរួមរបស់ស្ត្រីដូចជា ការធានាភាពជាតំណាងស្មើភាពគ្នារវាងបុរសនិងស្ត្រីនៅក្នុងកម្មវិធីនានា និងនៅគ្រប់ពេលតែងលើកឡើងពីឋានៈផ្លូវច្បាប់ស្មើភាពគ្នារវាងបុរស និងស្ត្រីទាក់ទងនឹងសិទ្ធិមនុស្ស។

ក្នុងនាមជាថ្នាក់ដឹកនាំសហគមន៍ ឬសកម្មជនសង្គមស៊ីវិល អ្នកការពារសិទ្ធិមនុស្សជាស្ត្រីដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់ ការពង្រឹង និងការការពារដល់សិទ្ធិមនុស្ស។ ម.ស.ម.ក បានកត់សម្គាល់ និងមានការព្រួយបារម្ភថា អ្នកការពារសិទ្ធិមនុស្សជាស្ត្រីទទួលរងការរំលោភបំពាន និងការបំពារបំពានផ្សេងៗជាច្រើន រួមមានទាំងអំពើហិង្សាដោយផ្អែកលើភេទជាដើម ដែលជាឫសគល់នាំឱ្យមានការរើសអើងនាពេលកន្លងមក ហើយទំនៀមទម្លាប់ប្រពៃណីផ្ដល់ការអនុគ្រោះចំពោះអំពើហិង្សាទៅលើស្ត្រី។ ហេតុដូច្នេះហើយ ម.ស.ម.ក នឹងនៅតែផ្ដល់ការគាំទ្រផ្នែកមនុស្សធម៌ ចិត្តសាស្ត្រ និងច្បាប់សមគួរតាមលទ្ធភាពទៅដល់អ្នកការពារសិទ្ធិមនុស្សជាស្ត្រីដែលប្រឈមនឹងអំពើហិង្សា ការយាយី និងការគំរាមកំហែងដោយសារការងាររបស់ពួកគាត់។

## V. ឧបសម្ព័ន ៖ ឯកសារបោះពុម្ពផ្សាយសំខាន់ៗរបស់ ម.ស.ម.ក

- របាយការណ៍ស្ដីពី ការរើសអើងលើអ្នកប្ដូរភេទជាស្ត្រីនៅតាមទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា
- របាយការណ៍ស្ដីពី ស្ត្រីក្នុងជម្លោះដីធ្លីនៅកម្ពុជា។
- សៀវភៅណែនាំស្ដីពីធុរកិច្ចនិងសិទ្ធិមនុស្សនៅកម្ពុជា ។
- របាយការណ៍ស្ដីពីការទទួលបានបណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា។

--- ចប់ ---